**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ៧៣៥ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការគ្រប់គ្រងទំនិញកំណត់ពិសេស

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខនស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០៩ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**ប្រការ ១.-**

ទំនិញកំណត់ពិសេស គឺជាប្រភេទទំនិញដែលមានវេទយិតភាព ឬទំនិញដែលជាប់ពន្ធខ្ពស់ស្របតាមបញ្ញត្តិកថាខណ្ឌទី ២ មាត្រា ៨ នៃច្បាប់ស្តីពីគយ ។ ទំនិញកំណត់ពិសេសជាកម្មវត្ថុនៃការកំណត់បន្ថែមនូវនីតិវិធីនៃការត្រួតពិនិត្យ និងការដាក់កម្រិតកំណត់លើការដឹកជញ្ជូន ការធ្វើចរាចរ ការធ្វើសន្និធិ និងការកាន់រក្សាទំនិញទាំងនេះ ។

**ប្រការ ២.-**

ទំនិញជាប់ពន្ធខ្ពស់ គឺជាប្រភេទទំនិញដែលត្រូវជាប់កាតព្វកិច្ចពន្ធ និងអាករនាំចូលតាមអត្រាគរពូន (Compound Rate) លើសពី ២៧ ( ម្ភៃប្រាំពីរ ) ភាគរយ ។

**ប្រការ ៣.-**

ទំនិញមានវេទយិតភាព គឺជាប្រភេទទំនិញដែល :

- ស្ថិតក្នុងបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ ស្របតាមបញ្ញត្តិនៃអនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់
- មានសក្តានុពលពាក់ព័ន្ធនឹងចំណូលពន្ធ អាករនាំចូល និងអំពើគេចពន្ធ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ៤.-**

សម្រាប់មុខទំនិញដែលជាទំនិញកំណត់ពិសេស ដូចមានចែងក្នុងប្រការ ១ ប្រការ ២ និងប្រការ ៣ នៃប្រកាសនេះ សិទ្ធិអំណាចរបស់មន្ត្រីគយ និងរដ្ឋាករស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីគយ ត្រូវគ្របដណ្តប់នៅទូទាំងដែនគយ រាប់បញ្ចូលទាំងក្នុងវង់អំណាចគយផងដែរ ។

ចំពោះមុខទំនិញផ្សេងទៀតដែលពុំមែនជាទំនិញកំណត់ពិសេស សិទ្ធិអំណាចរបស់មន្ត្រីគយ និងរដ្ឋាករ ស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីគយ ត្រូវគ្របដណ្តប់តែក្នុងវង់អំណាចគយប៉ុណ្ណោះ ។

ក្នុងករណីមានការដេញប្រដាប់ចាប់ប្រតិពីក្នុងវង់អំណាចគយឬការរកឃើញដោយចៃដន្យនូវទំនិញដែលមិនស៊ីគ្នានឹងការប្រកាស ឬឯកសារដែលមានជាប់នឹងអ្នកកាន់កាប់ សិទ្ធិអំណាចរបស់មន្ត្រីគយ និងរដ្ឋាករស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីគយ អាចគ្របដណ្តប់នៅទូទាំងដែនគយ ទោះបីទំនិញនេះពុំមែនជាប្រភេទទំនិញកំណត់ពិសេសក្តី ។

**ប្រការ ៥.-**

ក្នុងករណីចាំបាច់ នាយកដ្ឋានទីចាត់ការគយ និងរដ្ឋាករ អាចស្នើសុំការសម្រេចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការកែសម្រួល ឬបំពេញបន្ថែមមុខទំនិញនៅក្នុងបញ្ជីទំនិញកំណត់ពិសេស ។

**ប្រការ ៦.-**

យោងទៅតាមកាលៈទេសៈជាក់ស្តែង និងដើម្បីធានាប្រសិទ្ធភាពការងារគយ និងរដ្ឋាករ នាយកដ្ឋានទីចាត់ការគយ និងរដ្ឋាករ អាចកំណត់ និងកែសម្រួលពីពេលមួយទៅ

ពេលមួយនូវនីតិវិធីគយពាក់ព័ន្ធនឹងការដឹកជញ្ជូន ការចែកចាយ ការធ្វើសន្និធិ និងការកាន់រក្សាទំនិញកំណត់ពិសេស រួមទាំងលទ្ធភាពនៃ ការតម្រូវឱ្យបិទលតាប័ត្រ ឬត្រាគយ ការតម្រូវឱ្យដឹកជញ្ជូនដោយមធ្យោបាយមានការអនុញ្ញាត ការតម្រូវឱ្យគ្រប់គ្រងចុះបញ្ជីដោយឡែក និងការតម្រូវឱ្យដាក់ឯកសារគតិយុត្តិពាក់ព័ន្ធអមភ្ជាប់នឹងទំនិញនេះជាដើម ។

**ប្រការ ៧.-**

អ្នកនាំចេញ អ្នកនាំចូល ម្ចាស់ទំនិញ ឬតំណាងម្ចាស់ទំនិញកំណត់ពិសេស មានការកិច្ចអនុវត្តឱ្យបានត្រឹមត្រូវតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ ពាក់ព័ន្ធនឹងនីតិវិធីនៃការដឹកជញ្ជូន ការធ្វើចរាចរ ការធ្វើសន្និធិ ការកាន់រក្សា និងការតម្រូវផ្សេងទៀតពាក់ព័ន្ធនឹងទំនិញកំណត់ពិសេស ។

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩.-**

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ទីចាត់ការគយ និងរដ្ឋាករ
- ដូចប្រការ ៩
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ឧបសម្ព័ន្ធ

*នៃប្រកាសលេខ:៧៣៩សហវ.គរ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៨ របស់*

*ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី ការគ្រប់គ្រងទំនិញកំណត់ពិសេស*

**១. បញ្ជីមុខទំនិញកំណត់ពិសេស** : មុខទំនិញកំណត់ពិសេសរួមមាន ៖

- មុខទំនិញជាប់ពន្ធខ្ពស់តាមបញ្ញត្តិប្រការ ២ នៃប្រកាសស្តីពីការគ្រប់គ្រងទំនិញកំណត់ពិសេស

- មុខទំនិញស្ថិតនៅក្នុងបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ក្នុងការនាំចេញ ឬនាំចូល ស្របតាមបញ្ញត្តិនៃអនុក្រឹត្យស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់

- មុខទំនិញផ្សេងៗទៀតដូចមានចែងខាងក្រោម :

១. បន្លែ ផ្លែឈើ មើមឈើ ត្រី សាច់ គ្រប់ប្រភេទ

២. មេ្សៅមី

៣. ប្រេងឆា

៤. គ្រឿងឧបភោគ បរិភោគ

៥. សុរា និងស្រាបៀរ

៦. ទឹកដោះគោក្នុងទម្រង់ការ ខាប់ ឬម្សៅ ទោះមានជាតិស្ករក្តី

៧. ភេសជ្ជៈគ្រប់ប្រភេទទោះគ្មានជាតិស្ករ ឬគ្មានជាតិអាល់កុលក្តី

៨. បារីគ្រប់ប្រភេទ

៩. ផលិតផលតេលសិលា

១០. ប៊ីចេង

១១. ប្រេងខ្យល់ និងប្រេងកូឡា

១២. ផលិផលគ្រឿងសម្អាង

១៣. សាប៊ូ ឬផលិតផលសម្រាប់លាងសម្អាត និងថែរក្សាអនាម័យ

១៤. សំបកកង់យានយន្ត និងគ្រឿងចក្រ

១៥. ក្រដាសគ្រប់ប្រភេទ

១៦. ក្រណាត់ សម្លៀកបំពាក់ រួមទាំងគ្រឿងផ្សំ ឬបំណែក

១៧. ម៉ាស៊ីន ឬបរិធានមេកានិកអគ្គិសនី ឬអេឡិចត្រូនិច រួមទាំងគ្រឿងបន្លាស់ និងបំណែក

១៨. ម៉ាស៊ីនភ្លើង អាគុយ ថ្មពិល

១៩. ឧបករណ៍ និងបរិក្ខារទូរគមនាគមន៍ រួមទាំងគ្រឿងបន្សំ

២០. យានយន្ត និងគ្រឿងចក្រ រួមទាំងគ្រឿងបន្លាស់ និងបំណែក

២១. ឧបករណ៍ និងសម្ភារៈល្បែងគ្រប់ប្រភេទ

**២. កំណត់សម្គាល់**

- ការបិទត្រាពន្ធគយលើមុខទំនិញនីមួយៗ ត្រូវអនុវត្តតាមបញ្ញត្តិនៃសេចក្តីជូនដំណឹងលេខ ០៦២ សហវ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការបិទត្រាពន្ធគយ លើទំនិញមួយចំនួនដែលនាំចូលក្រោមរបបនាំចូលស្ថាពរ ដោយបង់ពន្ធ និងអាករតាមច្បាប់ជាធរមាន និងតាមសេចក្តីណែនាំផ្លូវការពីពេលមួយទៅពេលមួយរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

- ការបិទលតាប័ត្រលើយានយន្ត ឬគ្រឿងចក្រគ្រប់ប្រភេទត្រូវអនុលោមតាមបញ្ញត្តិជាធរមាននានាពាក់ព័ន្ធនឹងការគ្រប់គ្រងលតាប័ត្រយានយន្ត ។